# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ផ្លូវប្រតិបត្តិចេញចាកទុក្ខ

www.hoksavann.org

ថ្ងៃទី២១ កុម្ភៈ ២០១៣



*ព្រះពុទ្ធបានប្រកាសនៅពេលដែលព្រះអង្គបានសំដែងធម៌ទេសនាប្រោសភិក្ខុ៥អង្គថា ផ្លូវអមខាងទាំងពីរ គឺទី១ ឈ្មោះ* ***«កាមសុខល្លិកានុយោគ»*** *ចិត្តត្រេកអរដោយសេចក្ដីសុខក្នុងកាមគុណទាំង៥គឺ រូប សម្លេង ក្លិន រស និង សម្ផស្ស ជាធម៌របស់អ្នកស្រុក ជាធម៌ថោកទាប ជាធម៌របស់មនុស្សបុថុជ្ជន ពុំមែនជាធម៌របស់អរិយបុគ្គល ដែលនាំឲ្យឃើញអរិយ-សច្ច៤ទេ មិនប្រកបដោយប្រយោជន៍ឡើយ ព្រោះការជាប់ចិត្តយ៉ាងនេះ នាំឲ្យខ្សោយបញ្ញា មិនអាចត្រាស់ដឹងបានឡើយ ។ តថាគតធ្លាប់បានជួបផ្លូវនេះរួចហើយ កាលនៅក្នុងព្រះបរមរាជវាំង ។ ផ្លូវនេះចាត់ទុកជាផ្លូវអមខាង ជាផ្លូវស្ដាំផុត ។ ផ្លូវទី២ ឈ្មោះ* ***«អត្តកិលមថានុយោគ»*** *ព្យាយាមប្រព្រឹត្តធ្វើឲ្យលំបាកកាយដោយវិធីផ្សេងៗ មានខែត្រជាក់ចុះត្រាំទឹក ខែក្ដៅឈរឬអង្គុយហាលថ្ងៃ ឈរតែជើងម្ខាង ដេកលើបន្លា ដកដង្ហើមតិចៗ បន្ថយអាហារ ដើម្បីឲ្យស្ងួតកិលេស ដោយយល់ខុសថាកិលេសនៅក្នុងកាយ ។ ធម៌នេះធ្វើឲ្យលំបាកកាយ មិនមែនជាធម៌របស់អរិយបុគ្គលទេ មិនប្រកបដោយប្រយោជន៍ឡើយ ។ វិធីប្រតិបត្តិនេះ តថាគតធ្លាប់បានអនុវត្តហើយ ចាត់ទុកថាជាផ្លូវអមខាងផ្លូវឆ្វេងផុត ។*

*ព្រះសម្ពុទ្ធជាកំពូលនៃលោកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ* ***«មជ្ឈិមា បដិបទា»*** *ជាផ្លូវប្រតិបត្តិកណ្ដាល ព្រោះឃើញទោសនៃផ្លូវអមខាងទាំងពីរ ជាផ្លូវប្រតិបត្តិដើម្បីកើតបញ្ញាចក្ខុធ្វើឲ្យកើតសេចក្ដីដឹងច្បាស់ប្រាកដ ប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះដឹងប្រពៃដើម្បីរំលត់ទុក្ខ ។ មគ្គប្រកបដោយអង្គ៨នេះហៅថា ប្រតិបត្តិជាកណ្ដាលគឺ* ***«សម្មាទិដ្ឋិ»*** *ប្រាជ្ញាយល់ឃើញត្រូវ* ***«សម្មាសង្កប្បោ»*** *ការត្រិះរិះត្រូវ* ***«សម្មាវាចា»*** *វាចាត្រូវ* ***«សម្មាកម្មន្តោ»*** *ការងារត្រូវ* ***«សម្មាអាជីវោ»*** *ការចិញ្ចឹមជីវិតត្រូវ* ***«សម្មាវាយាមោ»*** *ការព្យាយាមត្រូវ* ***«សម្មាសតិ»*** *ការរលឹកត្រូវ និង* ***«សម្មាសមាធិ»*** *ការតម្កល់ចិត្តនឹងត្រូវ ។ បើរួមឲ្យខ្លីមានបីគឺ* ***«សីល សមាធិ បញ្ញា»*** *។* ***«សម្មាទិដ្ឋិ និង សម្មាសង្កប្បោ»*** *ជាតួបញ្ញា* ***«សម្មាវាចា សម្មាកម្មន្តោ និង សម្មាអាជីវោ»*** *ជាតួសីល ។* ***«សម្មាវាយាមោ សម្មាសតិ និងសម្មាសមាធិ»*** *ជាតួសមាធិ ។ អដ្ឋង្គិកមគ្គនេះ លោករៀងបញ្ញានៅខាងដើម ប្លែកពីត្រៃសិក្ខាដែលរៀងបញ្ញានៅខាងចុង គឺសីលសមាធិបញ្ញា មកពីវិធីបច្ចេកទេសរបស់ព្រះពុទ្ធក្នុងការសំដែងធម៌ទេសនាប្រោសភិក្ខុ៥អង្គ ។ ព្រះអង្គត្រូវតែសំដែងអំពីបញ្ញាមុន ដើម្បីឲ្យភិក្ខុ៥អង្គយល់ថា ព្រះពុទ្ធត្រាស់ដឹងហើយ ដើម្បីឲ្យភិក្ខុទាំងនោះយកចិត្តទុកដាក់ស្ដាប់ ព្រោះសីលនិងសមាធិ ភិក្ខុទាំងនោះធ្លាប់អនុវត្តមកហើយ ។ អ្នកសិក្សាព្រះពុទ្ធសាសនាគប្បីយល់ថា បញ្ញានេះជា* ***«បញ្ញាលោកុត្តរៈ»*** *កើតឡើងបានលុះត្រាតែមានសីលនិងសមាធិប្រកបជាមួយ ហើយពុំមែនជាបញ្ញាកើតពីការស្ដាប់ និងការត្រិះរិះពិចារណាជាតួបរិយត្តិធម៌នោះទេ តែជាតួបញ្ញាកើតពីការប្រតិបត្តិវិបស្សនាភាវនា ទើបកើតបញ្ញាជា «**លោកុត្តរៈ**» ជាបដិវេធធម៌ ឃើញអរិយសច្ច៤ ។ ការដើរតាមមគ្គប្រកបដោយអង្គ៨ឃើញអរិយសច្ច៤ គឺសេចក្ដីសុខបានដល់ការកើតឡើងនៃខន្ធ៥គឺ* ***«រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ១»*** *ហេតុដែលនាំឲ្យកើតទុក្ខបានដល់* ***«តណ្ហា១»*** *ការរលត់ទុក្ខបានដល់ការឈប់មានជាតិ១ ផ្លូវទៅកាន់ការរំលត់ទុក្ខ បានដល់មគ្គប្រកបដោយអង្គ៨ ដូចបានពោលមកហើយ១* ***(ទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច)*** *។ ការត្រាស់ដឹងរបស់ព្រះពុទ្ធមិនត្រឹមតែមនុស្សលោកទេ ដែលមានការរំភើបសប្បាយរីករាយ ដំណឹងនេះបានដឹងយ៉ាងឆាប់រហ័សដល់ពួកទេវតា ពួកព្រហ្ម បានសំដែងការកោតសរសើរចំពោះព្រះពុទ្ធឈ្នះមារ ដែលបានត្រាស់ដឹងរកឃើញការពិតសំរាប់រំដោះទុក្ខនៃមនុស្សសត្វ ដែលពីមុនគ្មានអ្នកណារកឃើញ ហើយសង្ឃឹមថា ខ្លួននឹងបានស្ដាប់ធម៌របស់ព្រះអង្គ ក៏ថ្វាយព្រះពរសព្វសាធុការតែរៀងៗខ្លួន ។មគ្គប្រកបដោយអង្គ៨នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធជាផ្លូវនៃការចេញចាកទុក្ខបានដល់អមតមហានិព្វាន ។ សមណព្រាហ្មណ៍និងតាបសឥសីមុនសម័យពុទ្ធកាល ក៏ដូចជាសម័យពុទ្ធកាល មិនបានឃើញផ្លូវនេះទេ ។ ក្រោយពីព្រះអង្គបានសិក្សា ពិសោធន៍គ្រប់បែបយ៉ាង និងដោយបារមីធម៌ដែលព្រះអង្គបានកសាងជួយជំរុញផង ទើបព្រះអង្គរកផ្លូវត្រាស់ដឹងនេះឃើញ ហើយដោយព្រះអង្គប្រតិបត្តិតាមផ្លូវនេះ* ***(មគ្គ៨)*** *ក៏បានត្រាស់ជាព្រះពុទ្ធក្នុងលោក គឺការឃើញអរិ-យសច្ច៤នេះឯង ។ សាសនាដទៃស្វែងរកសេចក្ដីសុខតែនៅក្នុងខន្ធ៥ មាន**រូបខន្ធ**ជាដើម ក្នុងស្ថានមនុស្សលោក ស្ថានទេវតា និងស្ថានព្រហ្ម ។ ព្រះពុទ្ធសំដែងថា ភពទាំងបីនេះស្ថិតនៅក្រោមត្រៃលក្ខណ៍ធម៌គឺ* ***អនិច្ចំ ទុក្ខំ និង អនត្តា*** *កើតចាស់ឈឺស្លាប់ មិនរួចពីសេចក្ដីទុក្ខទេ ជាវដ្ដសង្សារវិលកើតវិលស្លាប់រកទីបំផុតគ្មាន ។ ចំណែកព្រះនិព្វានទើបដល់ការរំលត់ទុក្ខ ពុំស្ថិតនៅក្រោមអំណាចមច្ចុរាជឡើយ ។ យើងបានឃើញរឿងក្នុងសាសនាព្រាហ្មណ៍និកាយព្រះវិស្ណុថា ពួកទេវតានិងពួកអសុរបានកាន់ក្បាលនាគនិងកន្ទុយនាគម្ខាងម្នាក់កូរសមុទ្រទឹកដោះ ដើម្បីរកទឹកអម្រឹតផឹកទៅមិនស្លាប់ ។ នេះជារឿងដំណាលប្រាសចាកការពិតរបស់សាសនាព្រាហ្មណ៍ ព្រោះអ្វី ព្រោះថាគ្មានទឹកណាផឹកទៅមិនស្លាប់នោះឡើយ ។ កាលណាមានជាតិ តែងតែបញ្ជូនទៅរកជរា ព្យាធិ និងមរណៈពុំខានឡើយ ។ ចំណែកព្រះនិព្វានទើបមិនស្លាប់ ទើបហៅថា* ***អមតមហានិព្វាន*** *។ ក្នុងធម៌អារាធនាព្រហ្មថា ញ៉ាំងសត្វចូលពុទ្ធចក្រមានបញ្ចវគ្គីយ៍ជាអាទិ ឲ្យផឹកអម្រឹតជាតិ រស-និព្វានតាមធម្មតា ។ ពាក្យថា* ***អម្រឹត*** *ជាពាក្យសំស្ក្រឹតប្រែថា មិនស្លាប់ ស្មើគ្នានឹងពាក្យបាលីថា* ***អមតំ*** *បានជាលោកពោលថា* ***អមតំ និព្វានំ*** *ប្រែថា និព្វានមិនស្លាប់ ដោយផឹកទឹកអម្រឹតជាតិគឺប្រតិបត្តិតាមមគ្គ៨ ។*

*ប្រតិបត្តិតាមមគ្គប្រកបដោយអង្គ៨ ដូចដែលបានពោលមកហើយ ទើបបានរសមួយ គឺនិព្វានរសជាធម៌មិនស្លាប់លែងវិលកើតវិលស្លាប់ក្នុងសង្សារវដ្តជាបន្តទៅទៀត ។៚*